ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្ដីពីអគ្គិសនី

## នៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣**

**ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ និងច្បាប់ស្ដីពីវិសោធនកម្មមាត្រា ៩ ឆ្នាំ២០០៧**

**ច្បាប់ស្ដីពីវិសោធនកម្មមាត្រា ៣ មាត្រា ៤ មាត្រ ៥ មាត្រា ២៦ មាត្រា ២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ ឆ្នាំ២០១៥**

# ព្រះរាជក្រម

នស/រកម/០២០១/០៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមិនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និងមាត្រាទាំងឡាយនៃជំពូក៨ ដល់ជំពូក១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី និងពីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបាន អនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញកាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែ កុម្ភៈ ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ហត្ថលេខា

**ស៊ុយ សែម**

# ព្រះរាជក្រម

នស/រកម/០៦០៧/០១៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពីរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៩ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៧០៦.២៦៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
**ហត្ថលេខា**
**ស៊ុយ សែម**

# ព្រះរាជក្រម

**នស/រកម/០៥១៥/០០៥**

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រងយល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាល

ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី ៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ពរល.១៥០៥.៤៥៦

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
**ហត្ថលេខា**
**ស៊ុយ សែម**

# ច្បាប់

## ស្ដីពី

## អគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

(កែសម្រួលតាមវិសោធនកម្មលើកទី១ លើមាត្រា ៩ នៃច្បាប់ស្ដីពីអគ្គិសនី

នៃព្រះរាជាណាចក្រកម្ពុជា និងវិសោធនកម្មលើកទី២ លើមាត្រា៣ មាត្រា៤ មាត្រា៥
មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្ដីពីអគ្គិសនី

នៃព្រះរាជាណាចក្រកម្ពុជា)

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងគ្រប់គ្រង និងរៀបចំក្របខណ្ឌការងារសម្រាប់ការផ្គត់ផ្គង់ និងសេវាកម្មអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះមានវិសាលភាពលើរាល់សកម្មភាពនៃការផ្គត់ផ្គង់ ការផ្តល់សេវា ការប្រើប្រាស់អគ្គិសនី និងសកម្មភាពផ្សេងៗទៀតលើវិស័យអគ្គិសនី ។

អគ្គិសនីក្នុងច្បាប់នេះ សំដៅលើថាមពលអគ្គិសនី ឬសមត្ថភាពក្នុងការផលិតថាមពលអគ្គិសនី ។

សេវាកម្មអគ្គិសនីក្នុងច្បាប់នេះ សំដៅលើការផលិត ការបញ្ជូន និងការចែកចាយអគ្គិសនីព្រមទាំងសេវាកម្មបន្ថែម ឬបន្ទាប់បន្សំភ្ជាប់ជាមួយសកម្មភាពទាំងនេះ ។

**មាត្រា ២.-**

ច្បាប់នេះសំដៅបង្កើតឡើងនូវ ៖

ក- គោលការណ៍សម្រាប់កិច្ចប្រតិបត្តិការវិស័យអគ្គិសនី និងរាល់សកម្មភាពរបស់អ្នកកាន់អាជ្ញាបណ្ណក្នុងការផ្តល់សេវាកម្មអគ្គិសនី

ខ- លក្ខខណ្ឌសមស្របក្នុងការវិនិយោគទុន និងកិច្ចប្រតិបត្តិការពាណិជ្ជកម្មក្នុងវិស័យអគ្គិសនី

គ- មូលដ្ឋានសម្រាប់បញ្ញត្តិចំពោះការផ្គត់ផ្គង់សេវាកម្មអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា

ឃ- គោលការណ៍សម្រាប់ ៖

១- ការពារសិទ្ធិអ្នកប្រើប្រាស់ដើម្បីទទួលបាននូវការផ្គត់ផ្គង់សេវាកម្មអគ្គិសនីដែលមានស្ថេរភាព និងគ្រប់គ្រាន់តាមតម្លៃសមរម្យ

២- បង្កើនកម្មសិទ្ធិឯកជនលើមធ្យោបាយសម្រាប់ការផ្តល់សេវាកម្មអគ្គិសនី

៣- បង្កើតការប្រកួតប្រជែងនៅទីណាដែលអាចធ្វើទៅបានក្នុងផ្នែកអគ្គិសនី

ង- គោលការណ៍ក្នុងការផ្តល់សិទ្ធិ កាតព្វកិច្ចនិងធ្វើការពិន័យចំពោះអ្នកផ្គត់ផ្គង់ អ្នកប្រើប្រាស់អគ្គិសនី សាធារណជន និងម្ចាស់កម្មសិទ្ធិទីតាំងដែលទាក់ទិនដល់មធ្យោបាយផលិត និងផ្គត់ផ្គង់អគ្គិសនី និង

ច- អាជ្ញាធរអគ្គិសនីកម្ពុជាសម្រាប់បញ្ញត្តិចំពោះការផ្តល់សេវាកម្មអគ្គិសនី ។

អ្នកប្រើប្រាស់ក្នុងន័យនៃច្បាប់នេះសំដៅលើបុគ្គលណាមួយ ឬអ្នកទទួលសិទ្ធិបន្តដែលទិញ ឬទទួលអគ្គិសនីដើម្បីប្រើប្រាស់ និងមិនមែនដើម្បីផ្តល់ ឬលក់បន្តឲ្យអ្នកដទៃទៀត។

## ជំពូកទី ២
## ក្របខណ្ឌការងារនៃការផ្គត់ផ្គង់និងសេវាកម្មអគ្គិសនី

**មាត្រា ៣.- ថ្មី** *

ការរៀបចំ និងការគ្រប់គ្រងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាលលើវិស័យអគ្គិសនីជាសមត្ថកិច្ចទទួលខុសត្រូវទូទៅរបស់ក្រសួងរ៉ែ និងថាមពល ។

ការធានាឲ្យការផ្តល់សេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនីប្រព្រឹត្តទៅដោយប្រសិទ្ធភាព គុណភាព ចីរភាព និងមានតម្លាភាព ជាសមត្ថកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

**មាត្រា ៤.- ថ្មី** *

ក្រសួងរ៉ែ និងថាមពល ត្រូវផ្តល់ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការវិស័យអគ្គិសនី និងសេចក្តីសម្រេចនានាជាអាទិ៍ស្តីពី៖

- ការវិនិយោគលើការស្តារ និងការអភិវឌ្ឍវិស័យអគ្គិសនីសម្រាប់រយៈពេលខ្លី មធ្យម និងវែង
- ការរៀបចំឡើងវិញ ការចូលរួមរបស់ផ្នែកឯកជន និងឯកជនូបនីយកម្មរបស់សហគ្រាសសាធារណៈ
- ការលើកទឹកចិត្តចំពោះការប្រើប្រាស់ធនធានថាមពលដែលមានស្រាប់ក្នុងស្រុកសម្រាប់ការផលិតអគ្គិសនី
- ការរៀបចំផែនការ និងកិច្ចព្រមព្រៀងលើការនាំចេញ នាំចូលអគ្គិសនី
- ការឧបត្ថម្ភក្រុមអ្នកជាវជាកំណត់ណាមួយ និងការផ្តល់អាទិភាពដល់អ្នកប្រើប្រាស់អគ្គិសនី
- ការបង្កើនប្រសិទ្ធភាពក្នុងការផលិត បញ្ជូនចែកចាយអគ្គិសនី និងការប្រើប្រាស់អគ្គិសនីព្រមទាំងសកម្មភាពដើម្បីបង្កើតកម្មវិធីសន្សំសំចៃអគ្គិសនីសម្រាប់កម្ពុជា និង
- កាលៈទេសៈដែលមានភ័យន្តរាយផ្នែកអគ្គិសនី និងយុទ្ធសាស្ត្រដើម្បីធានាសន្តិសុខផ្នែកថាមពល ។

រាល់ការសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការក្នុងវិស័យអគ្គិសនី ត្រូវស្ថិតនៅក្នុងក្របខណ្ឌនៃគោលនយោបាយ យុទ្ធសាស្ត្រ ផែនការវិស័យអគ្គិសនី និងសេចក្តីសម្រេចនានាខាងលើ ។

**មាត្រា ៥.- ថ្មី** *

អ្នកផ្គត់ផ្គង់សេវាកម្មអគ្គិសនីនីមួយៗ ត្រូវមានអាជ្ញាបណ្ណដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ហើយត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងរាល់បញ្ញត្តិដែលកំណត់ក្នុងអាជ្ញាបណ្ណរបស់ខ្លួន ព្រមទាំងបទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងការតម្រូវតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

រាល់ការសម្រេចចេញអាជ្ញាបណ្ណត្រូវផ្អែកលើគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការលើវិស័យអគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគោលបំណងកាត់បន្ថយចំណាយម៉ាហ្ស៊ីណាល់រយៈពេលវែង និងខ្លីឲ្យនៅតិចបំផុត ក្នុងការផ្គត់ផ្គង់អគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសេចក្តីសម្រេចនានាដូចមានចែងក្នុងមាត្រា ៤ថ្មី ហើយត្រូវធានាដល់ផលប្រយោជន៍សាធារណៈ ។

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាឲ្យអ្នកកាន់អាជ្ញាបណ្ណប្រតិបត្តិតាមស្តង់ដាទាក់ទងទៅនឹងកិច្ចប្រតិបត្តិ-ការ បច្ចេកទេស សុវត្ថិភាព និងបរិស្ថាន ដែលបង្កើតឡើងនិងផ្សព្វផ្សាយដោយក្រសួងរ៉ែ និងថាមពល ។

( * ) សូមមើលមាត្រាកែប្រែ ទំព័រ ៣០

អាជ្ញាបណ្ណក្នុងច្បាប់នេះ សំដៅលើលិខិតអនុញ្ញាតដើម្បីធ្វើសេវាកម្មអគ្គិសនី ។

អ្នកកាន់អាជ្ញាប័ណ្ណក្នុងច្បាប់នេះសំដៅលើបុគ្គលដែលកាន់កាប់អាជ្ញាបណ្ណស្របច្បាប់ និងមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

## ជំពូកទី ៣
## ការរៀបចំអាជ្ញាធរអគ្គិសនីកម្ពុជា

**មាត្រា ៦.-**

អាជ្ញាធរអគ្គិសនីកម្ពុជាគឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលនូវសិទ្ធិពីរាជរដ្ឋាភិបាលនិងមានស្វ័យភាពក្នុងការត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី និងគ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី ។

**មាត្រា ៧.-**

អាជ្ញាធរអគ្គិសនីកម្ពុជាមានភារកិច្ចដូចតទៅ៖

ក- ចេញ កែសម្រួល ព្យួរ ដកហូត ឬបដិសេធអាជ្ញាបណ្ណសម្រាប់ការផ្គត់ផ្គង់សេវាកម្មអគ្គិសនី ដូចមានកំណត់ក្នុងមាត្រា ២៩ នៃច្បាប់នេះ

ខ- អនុម័តថ្លៃ និងបន្ទុកចំណាយផ្សេងៗព្រមទាំងលក្ខខណ្ឌនៃសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាបណ្ណ លើកលែងតែថ្លៃនិងបន្ទុកចំណាយផ្សេងៗព្រមទាំងលក្ខខណ្ឌទាំងនោះត្រូវបានបង្កើតឡើងតាមវិធីប្រកួតប្រជែង និងផ្អែកលើទីផ្សារ

គ- កំណត់ឲ្យអនុវត្តបញ្ញត្តិ បែបបទ និងស្តង់ដាសម្រាប់កម្មវិធីវិនិយោគរបស់អ្នកកាន់អាជ្ញាបណ្ណ

ឃ- ពិនិត្យឡើងវិញលើសកម្មភាពហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធសហគ្រាសរបស់អ្នកកាន់អាជ្ញាបណ្ណក្នុងកម្រិតមួយដែលសកម្មភាព និងរចនាសម្ព័ន្ធនោះអាចជាឧបសគ្គដោយផ្ទាល់ដល់កិច្ចប្រតិបត្តិការនៃវិស័យអគ្គិសនីនិងប្រសិទ្ធិភាពនៃការផ្គត់ផ្គង់អគ្គិសនី

ង- អនុម័តនិងដាក់ឲ្យអនុវត្តស្តង់ដាប្រតិបត្តិសម្រាប់អ្នកកាន់អាជ្ញាបណ្ណ

ច- វាយតម្លៃនិងសម្រុះសម្រួលបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់ និងវិវាទកិច្ចសន្យាដែលពាក់ព័ន្ធនឹងអ្នកកាន់អាជ្ញាបណ្ណ ក្នុងករណីដែលការតវ៉ានិងវិវាទនោះ ទាក់ទិននឹងការរំលោភបំពានលើលក្ខខណ្ឌដែលមានកំណត់ក្នុងអាជ្ញាបណ្ណ

ឆ- អនុម័ត និងដាក់ឲ្យប្រតិបត្តិនូវប្រព័ន្ធគណនីឯកភាពសម្រាប់អ្នកកាន់អាជ្ញាបណ្ណទាំងអស់

ជ- រៀបចំនិងផ្សព្វផ្សាយរបាយការណ៍លើវិស័យអគ្គិសនី និងព័ត៌មានពាក់ព័ន្ធនានាដែលទទួលពីអ្នកកាន់អាជ្ញាបណ្ណសម្រាប់ជាផលប្រយោជន៍ដល់រាជរដ្ឋាភិបាល និងផលប្រយោជន៍សាធារណៈ

ឈ- កំណត់កម្រៃនានាដែលត្រូវអនុវត្តលើអ្នកកាន់អាជ្ញាបណ្ណ

៣- កំណត់បែបបទសម្រាប់ការផ្តល់ព័ត៌មានដល់សាធារណជន អំពីកិច្ចការក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីជានាឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអនុវត្តទៅតាមគោលការណ៍តម្លាភាព ដូចមានចែងក្នុងមាត្រា ៣ នៃច្បាប់នេះ

ដ- ចេញបញ្ញត្តិ និងបទបញ្ជាសមស្របព្រមទាំងបញ្ជាផ្អាកជាបណ្តោះអាសន្ន និងជាស្ថាពរចំពោះសេវាកម្មអគ្គិសនី

ឋ- ពិន័យជាប្រាក់ ផ្អាកការប្រើប្រាស់អគ្គិសនី ឭូរ ឬដកហូតអាជ្ញាបណ្ណចំពោះការរំលោភលើច្បាប់នេះ និងលិខិតបទដ្ឋាននានាព្រមទាំងបញ្ញត្តិផ្សេងៗទៀតរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

ឌ- តម្រូវឲ្យអ្នកធ្វើសេវាកម្ម និងអ្នកប្រើប្រាស់អគ្គិសនីគោរពប្រតិបត្តិនូវរាល់វិធានដែលទាក់ទងនឹងសន្តិសុខ ថាមពល សេដ្ឋកិច្ច បរិស្ថានរបស់ប្រទេសជាតិព្រមទាំងគោលនយោបាយដទៃទៀតរបស់រាជរដ្ឋាភិបាល

ឍ- ចាត់វិធានការផ្សេងទៀតចំពោះបញ្ហាបន្ទាប់បន្សំ ឬដែលជាផលវិបាកស្តែងចេញពីមុខងារដូចបានរៀបរាប់ខាងលើនេះ និង

ណ- បង្កើតលក្ខខណ្ឌជ្រើសរើស និងប្រើប្រាស់មន្ត្រីឬបុគ្គលិកអាជ្ញាធរអគ្គិសនីកម្ពុជាព្រមទាំងជំនាញការ ឬទីប្រឹក្សា ។

**មាត្រា ៨.-**

អាជ្ញាធរអគ្គិសនីកម្ពុជាមានលេខាធិការដ្ឋាន និងនាយកដ្ឋានជំនាញនានាជាសេនាធិការ ។

លេខាធិការដ្ឋានដែលដឹកនាំដោយនាយកប្រតិបត្តិ ១រូប ត្រូវបានបង្កើតឡើង ដើម្បីបម្រើកិច្ចការរដ្ឋបាល និងជំនាញបច្ចេកទេស ហើយមាននាយកដ្ឋានជំនាញក្រោមចំណុះ ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃលេខាធិការដ្ឋានត្រូវចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

**មាត្រា ៩.- ថ្មី** *

អាជ្ញាធរអគ្គិសនីកម្ពុជាមានសមាជិកទាំងអស់ ៣រូប ដែលក្នុងនោះមាន ១រូបជាប្រធាន ។ ប្រធាន និងសមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។ សមាជិកនីមួយៗ ត្រូវមានអាណត្តិ ៣ (បី)ឆ្នាំ ហើយត្រូវបញ្ចប់ក្នុងពេលខុសៗគ្នា លើកលែងតែក្នុងអាណត្តិដំបូងដូចមានចែងក្នុងមាត្រា ៧២ នៃច្បាប់នេះ ។

សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាអាចត្រូវបានតែងតាំងសម្រាប់អាណត្តិបន្តទៀតបាន ។

ក្នុងកំឡុង ២ (ពីរ)ឆ្នាំ ក្រោយការបញ្ចប់អាណត្តិរបស់ខ្លួន សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាមិនត្រូវចូលបម្រើការងារ ឬទំនាក់ទំនងជាទីប្រឹក្សា ឬជាអ្នកពិគ្រោះយោបល់ឲ្យអ្នកកាន់អាជ្ញាប័ណ្ណណាមួយឡើយ ។

**មាត្រា ១០.-**

បុគ្គលដែលត្រូវបានស្នើតែងតាំងជាប្រធាន ឬជាសមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ ៖

- មានសញ្ជាតិខ្មែរពីកំណើត និងមានសិទ្ធិបោះឆ្នោត

( * ) សូមមើលមាត្រាកែប្រែ ទំព័រ ៣០

- មិនដែលមានទោសពីបទល្មើសព្រហ្មទណ្ឌណាមួយ
- មានសញ្ញាប័ត្រចាប់ពីកម្រិតឧត្តមសិក្សាឡើងទៅក្នុងផ្នែកវិស្វកម្មអគ្គិសនី នីតិសាស្ត្រ សេដ្ឋកិច្ច គណនេយ្យ ហិរញ្ញកិច្ច ឬវិស្វករដែលមានជំនាញនិងឯកទេសពាក់ព័ន្ធក្នុងវិស័យនោះ ដែលមានការបញ្ជាក់ទទួលស្គាល់ច្បាស់លាស់ពីស្ថាប័នមានសមត្ថកិច្ច
- មានបទពិសោធន៍ការងារជំនាញយ៉ាងតិច ១០ (ដប់) ឆ្នាំ និង
- មានសមត្ថភាពការងារ ភាពស្អាតស្អំ និងគុណធម៌ ។

ការស្នើតែងតាំងនេះមិនផ្អែកលើនិន្នាការគណបក្សនយោបាយជាមូលដ្ឋានឡើយ ។

**មាត្រា ១១.-**

សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើការពេញម៉ោងនៅក្នុងអាជ្ញាធរអគ្គិសនីកម្ពុជា និងមិនត្រូវធ្វើការងារផ្សេងទៀត ឬយល់ព្រមទទួលកម្រៃពីសកម្មភាពផ្សេងៗទៀតបានឡើយ ។

**មាត្រា ១២.-**

សមាជិកព្រមទាំងមន្ត្រីទាំងអស់របស់អាជ្ញាធរអគ្គិសនីកម្ពុជា មិនអាចមានភាគហ៊ុនដោយផ្ទាល់ ឬមានផលប្រយោជន៍សេដ្ឋកិច្ច ឬមានមុខនាទីជាមួយអ្នកកាន់អាជ្ញាបណ្ណ ឬអ្នកសុំអាជ្ញាបណ្ណបានឡើយ ប៉ុន្តែអាចធ្វើជាអ្នកជាវរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

មិនអនុញ្ញាតឲ្យអ្នកកាន់អាជ្ញាបណ្ណ ឬតំណាងរបស់ខ្លួនផ្តល់អំណោយ ជំនូន ឬអត្ថប្រយោជន៍ផ្សេងៗទៀត ដែលខុសពីការអនុវត្តទូទៅចំពោះសាធារណជនដល់សមាជិកព្រមទាំងមន្ត្រីណាម្នាក់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ មិនអនុញ្ញាតឲ្យសមាជិកព្រមទាំងមន្ត្រីណាម្នាក់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ទទួលអំណោយ ជំនូន ឬអត្ថប្រយោជន៍ផ្សេងៗទៀតដែលខុសពីការអនុវត្តទូទៅចំពោះសាធារណជនពីអ្នកកាន់អាជ្ញាបណ្ណ ឬតំណាងរបស់ខ្លួន ។

ក្នុងអាណត្តិរបស់ខ្លួន សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាព្រមទាំងសហព័ទ្ធ ឬកូនមិនអាចរកការងារធ្វើ ឬចូលបម្រើការងារ ឬទទួលតំណែងណាមួយជាទីប្រឹក្សា ឬជាអ្នកពិគ្រោះការងារនិងមិនអាចមានភាគហ៊ុន ឬបណ្ណួតនាគារ ឬមានផលប្រយោជន៍ជាប្រាក់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ ឬជាមួយបុគ្គលដទៃទៀត ដែលមានទំនាក់ទំនងក្នុងការផ្តល់សេវាកម្មអគ្គិសនី ឬដំណើរការដែលពាក់ព័ន្ធណាមួយបានឡើយ ។

**មាត្រា ១៣.-**

ក្នុងអាណត្តិរបស់ខ្លួន សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាមានវិសមិតភាពជាមួយមុខងារជាមន្ត្រីរាជការ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាសមាជិកព្រឹទ្ធសភា ជាសមាជិករដ្ឋសភា ជាសមាជិកដែលមានតួនាទីក្នុងអង្គការដឹកនាំនៃគណបក្សនយោបាយណាមួយ ឬជាទីប្រឹក្សា ជំនួយការនៃស្ថាប័ន ឬសមាជិករាជរដ្ឋាភិបាល ។

នៅពេលបានទទួលការតែងតាំងជាសមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា សាមីជនដែលកំពុងបម្រើការងារដូចចែងក្នុងវាក្យខ័ណ្ឌខាងលើនេះ ត្រូវធ្វើលិខិតលាចេញពីមុខតំណែង ឬព្យួរការងារជាបណ្តោះអាសន្នសម្រាប់រយៈពេលបំពេញការងារក្នុងអាណត្តិរបស់ខ្លួន ។

**មាត្រា ១៤.-**

តំណែងជាសមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា ចាត់ទុកទំនេរនៅពេលដែលសាមីជន ៖

១- ទទួលមរណភាព

២- លាឈប់ពីតំណែង

៣- ចូលនិវត្តន៍

៤- ជាប់ទោសដាក់ពន្ធនាគារពីបទល្មើសព្រហ្មទណ្ឌណាមួយ

៥- បាត់បង់សិទ្ធិបោះឆ្នោត

៦- បាត់បង់សមត្ថភាពខាងបញ្ញា ឬកាយសម្បទា

៧- បានប្រព្រឹត្តល្មើសនឹងបញ្ញត្តិណាមួយ នៃមាត្រា ១១ មាត្រា១២ និងមាត្រា១៣

៨- មានការធ្វេសប្រហែសធ្ងន់ធ្ងរ និងខ្វះការទទួលខុសត្រូវក្នុងការបំពេញភារកិច្ច

៩- ប្រព្រឹត្តបទល្មើសមជ្ឈិមធ្ងន់ធ្ងរទាក់ទិននឹងមុខតំណែងរបស់ខ្លួន ឬ

១០- បោះបង់ការបំពេញភារកិច្ច ។

ប្រសិនបើសមាជិកណាម្នាក់មានការពាក់ព័ន្ធនឹងករណីនៃកថាខណ្ឌ៥ ៦ ៧ ៨ ៩ ឬ ១០ នាយករដ្ឋមន្ត្រីអាចសម្រេចព្យួរមុខតំណែងរបស់សមាជិកនោះ ហើយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច ។ នាយករដ្ឋមន្ត្រីតែងតាំងសមាជិកបណ្ដោះអាសន្នដើម្បីបំពេញការងារជំនួស ។

**មាត្រា ១៥.-**

នៅពេលតំណែងទំនេរកើតមានឡើងមុនផុតអាណត្តិ នាយករដ្ឋមន្ត្រីត្រូវជ្រើសរើសសមាជិកថ្មីជំនួសដើម្បីបំពេញអាណត្តិរបស់សមាជិកមុន ។ សមាជិកថ្មីនេះ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ។ ការបំពេញជំនួសនេះ ពុំត្រូវបានរាប់បញ្ចូលក្នុងចំនួនអាណត្តិពេញលេញ ដូចមានចែងក្នុងមាត្រា៩ ឡើយ ។

**មាត្រា ១៦.-**

បៀវត្សរ៍ ប្រាក់បំណាច់ និងអត្ថប្រយោជន៍ដទៃទៀតរបស់សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល ។ ប្រធានមានឋានៈស្មើនឹងរដ្ឋលេខាធិការ សមាជិកដទៃទៀតមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ។

សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវចូលនិវត្តន៍នៅពេលមានអាយុ ៦០ (ហុកសិប)ឆ្នាំ ។ ក្នុងករណីមានការចូលនិវត្តន៍មុនផុតអាណត្តិ នាយករដ្ឋមន្ត្រីអាចឲ្យបន្តការងាររហូតដល់បញ្ចប់អាណត្តិរបស់ខ្លួនតាមការចាំបាច់ជាក់ស្តែង ។

ប្រធាន ឬសមាជិកអាចសុំលាឈប់ពីតំណែងបានគ្រប់ពេលវេលាដោយធ្វើសំណើជាលាយល័ក្ខអក្សរផ្ញើជូននាយករដ្ឋមន្ត្រីយ៉ាងយឺតបំផុតឲ្យបាន១ (មួយ)ខែមុន ។

**មាត្រា ១៧.-**

ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជាមិនអាចត្រូវបានបញ្ឈប់ពីមុខតំណែងជាប្រធានមុនអាណត្តិរបស់ខ្លួនបានឡើយ លើកលែងតែក្នុងករណីណាមួយដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់នេះ ។

**មាត្រា ១៨.-**

ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវ ៖

- គ្រប់គ្រងអាជ្ញាធរអគ្គិសនីកម្ពុជា
- ដឹកនាំការប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា និង
- ធានាការផ្សព្វផ្សាយនិងអនុវត្តរាល់សេចក្ដីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

អាជ្ញាធរអគ្គិសនីកម្ពុជាអាចប្រគល់ជូនប្រធាននូវសិទ្ធិអំណាច និងភារកិច្ចជាបន្ថែមផ្សេងៗទៀត លើកលែងតែ ៖

- ការចេញ ការបដិសេធ ការកែប្រែ ឬការលុបចោលអាជ្ញាបណ្ណ
- ការច្រានចោលពាក្យសុំអាជ្ញាបណ្ណ ឬពាក្យសុំកែសម្រួលអាជ្ញាបណ្ណ
- ការកំណត់ ការអនុម័ត ការបដិសេធ ឬការកែប្រែថ្លៃអគ្គិសនី ឬកម្មវិធីវិនិយោគ និងកម្មវិធីទទួលអគ្គិសនី
- ការចេញ ការកែប្រែ ឬការលុបចោលបទប្បញ្ញត្តិនានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា ឬ
- ការសម្រេចលើពាក្យបណ្ដឹងតវ៉ារបស់សាធារណជន ។

ពាក្យបណ្ដឹងតវ៉ារបស់អ្នកមិនសុខចិត្តជាក្រុម ឬជាបុគ្គលអាចធ្វើទៅកាន់អាជ្ញាធរអគ្គិសនីកម្ពុជាបានក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់តាំងពីថ្ងៃប្រកាសសេចក្ដីសម្រេច ។

ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជាអាចចាត់តាំងសមាជិកណាមួយផ្សេងទៀតនៃអាជ្ញាធរអគ្គិសនីកម្ពុជាជាលាយល័ក្ខអក្សរ ដើម្បីបំពេញភារកិច្ចរបស់ប្រធានក្នុងពេលអវត្តមានរបស់ខ្លួន ។

**មាត្រា ១៩.-**

ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវតែងតាំងមន្ត្រីក្រោមឱវាទទាំងអស់ និងជួលអ្នកឯកទេសផ្សេងៗទៀតតាមតម្រូវការចាំបាច់សម្រាប់អនុវត្តភារកិច្ចអាជ្ញាធរអគ្គិសនីកម្ពុជាឲ្យបានត្រឹមត្រូវ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកឯទៀត ។ មន្ត្រី និងអ្នកឯកទេសរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ការងារ នៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤
## ការប្រព្រឹត្តិទៅរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

**មាត្រា ២០.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវអនុម័ត និងប្រកាសនូវវិធានសម្រាប់គ្រប់គ្រងការប្រជុំរវាងសមាជិក ឬមន្ត្រីអាជ្ញាធរអគ្គិសនីកម្ពុជា ជាមួយភាគីណាមួយអំពីការកសាងបញ្ជីថ្លៃលក់អគ្គិសនី ឬការផ្តល់អាជ្ញាបណ្ណ ។ វិធាននេះ ត្រូវកំណត់អំពីកម្មវត្ថុ កាលបរិច្ឆេទ ទីកន្លែង និងដំណើរការនៃការប្រជុំសំដៅផ្តល់លទ្ធភាពចូលរួមប្រជុំបានពីសំណាក់ភាគីពាក់ព័ន្ធ ។

**មាត្រា ២១.-**

សមាជិកទាំងអស់របស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវមានសម្លេងក្នុងការបោះឆ្នោតលើរាល់បញ្ហាដែលតម្រូវឲ្យមានការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ ការអនុម័តនេះត្រូវផ្អែកលើសម្លេងភាគច្រើន ។

ការអនុម័តរបស់អាជ្ញាធរអគ្គិសនីកម្ពុជាយកជាការបាន លុះត្រាតែមានវត្តមានសមាជិកពីររូបឡើងទៅ ។

សមាជិកទាំងអស់របស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបានទទួលដំណឹងស្តីពីកាលបរិច្ឆេទ ទីកន្លែង និងកម្មវត្ថុដែលត្រូវប្រជុំអនុម័ត ។

**មាត្រា ២២.-**

សម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាសម្រាប់សម្រុះសម្រួលពាក្យបណ្តឹងតវ៉ាត្រូវធ្វើឡើងជាសាធារណៈ ។ សេចក្តីសម្រេចដោយភ្ជាប់នឹងមូលហេតុរបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវប្រកាសជាសាធារណៈភ្លាម លើកលែងតែមានមូលហេតុណាមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចពន្យារការប្រកាសមួយរយៈសិន ។

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតម្កល់ទុក និងថែរក្សាការពាររាល់កំណត់ហេតុនៃពាក្យបណ្តឹងតវ៉ា បទបញ្ជា ការសន្និដ្ឋាន និងសេចក្តីសម្រេចនានា ព្រមទាំងសំណុំឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ ។

រាល់បទបញ្ជា ការសន្និដ្ឋាន សេចក្តីសម្រេច កំណត់ហេតុ និងសំណុំរឿងផ្សេងៗត្រូវដាក់ជូនសាធារណជនពិនិត្យដោយសេរី ក្នុងការិយាល័យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ប៉ុន្តែអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបង្កើតបទបញ្ជាដើម្បីធានាថា ព័ត៌មានសម្ងាត់ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានទទួល នៅតែរក្សាបានភាពសម្ងាត់ដដែល នៅពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថា ការរក្សាការសម្ងាត់នេះជាការចាំបាច់ ។

រាល់ការសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួនមិនត្រូវមានការជ្រៀតជ្រែកពីអាជ្ញាធរណាមួយ ឬពីភ្នាក់ងារណាមួយរបស់រាជរដ្ឋាភិបាលឡើយ លើកលែងតែមានចែងក្នុងច្បាប់នេះ ។

**មាត្រា ២៣.-**

មុនពេលប្រកាសឲ្យប្រើបទបញ្ជាទូទៅ ឬវិធាន ឬបទប្បញ្ញត្តិណាមួយ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវជូនដំណឹងពីខ្លឹមសារ ហើយត្រូវផ្តល់ឱកាសឲ្យនីតិបុគ្គលដែលពាក់ព័ន្ធ និងសាធារណជនបង្ហាញភស្តុតាង និងបញ្ចេញមតិយោបល់ ។ រាល់បទបញ្ជា វិធាន និងបទប្បញ្ញត្តិទាំងនោះ ត្រូវមានសម្រាប់សាធារណជន ។

មុនពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការសន្និដ្ឋានចេញបទបញ្ជា ឬសេចក្តីសម្រេចពាក់ព័ន្ធនីតិបុគ្គល ឬជនណាមួយ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវជូនដំណឹងសមស្របដល់នីតិបុគ្គល ឬជននោះអំពីពេលវេលានិងទីកន្លែងសម្រាប់នីតិបុគ្គល ឬជននោះ មានឱកាសផ្តល់ភស្តុតាងនិងបញ្ចេញមតិយោបល់ ។

**មាត្រា ២៤.-**

បន្ទាប់ពីអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចជាចុងក្រោយ ស្ថាប័ន និងភាគីពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។ ការប្តឹងតវ៉ានេះត្រូវអនុវត្តក្នុងរយៈពេល៣ (បី)ខែ ចាប់ពីថ្ងៃចេញសេចក្តីសម្រេចខាងលើ ។

**មាត្រា ២៥.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវទទួលខុសត្រូវរួមចំពោះផលវិបាកដែលកើតមានឡើងដោយការបំពេញភារកិច្ចរបស់សមាជិក ឬមន្ត្រីរបស់ខ្លួនក្នុងក្របខណ្ឌសមត្ថកិច្ចស្របតាមច្បាប់នេះ ព្រមទាំងអនុក្រឹត្យនិងបញ្ញត្តិនានាសម្រាប់អនុវត្តច្បាប់នេះ ។

**មាត្រា ២៦.- ថ្មី** *

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់បៀវត្សរ៍ និងប្រាក់បំណាច់របស់មន្ត្រី និងបុគ្គលិកក្រោមឱវាទ ។

អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបង្កើតគម្រោងថវិកាចំណាយកិច្ចប្រតិបត្តិការសម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដែលមានកំណត់ចំណូល និងចំណាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ ថវិកាត្រូវកំណត់ច្បាស់លាស់នូវកម្រៃអាជ្ញាបណ្ណសម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ រួមទាំងវិធីគណនាកម្រៃអាជ្ញាបណ្ណ ព្រមទាំងបៀវត្សរ៍ និងប្រាក់បំណាច់ផ្សេងទៀត ដែលត្រូវទូទាត់ជូនសមាជិក និងមន្ត្រីជាន់ខ្ពស់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវដាក់គម្រោងថវិកានេះជូនទៅរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៧.- ថ្មី** *

អាជ្ញាធរអគ្គិសនីកម្ពុជាមានថវិកាស្វយ័តមួយសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។ ថវិកានេះ គឺកម្រៃដែលអ្នកសុំអាជ្ញាបណ្ណ និងអ្នកកាន់អាជ្ញាបណ្ណត្រូវបង់តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ កម្រៃនេះហៅថា កម្រៃអាជ្ញាបណ្ណ ។

ថវិការបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតម្កល់ក្នុងគណនីមួយនៅធនាគាររបស់រដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា ។ មានតែអាជ្ញាធរអគ្គិសនីកម្ពុជាទេ ដែលមានសិទ្ធិប្រើប្រាស់ថវិកានេះ ។

កម្រិតអតិបរមានៃកម្រៃអាជ្ញាបណ្ណត្រូវកំណត់ដោយអនុក្រឹត្យ ។

ក្នុងករណីមានសំណល់ថវិកានៅដំណាច់ឆ្នាំណាមួយ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវផ្ទេរសំណល់ថវិកានេះទៅប្រើប្រាស់សម្រាប់គម្រោងថវិកាឆ្នាំបន្ទាប់ទៀត ។

ចំពោះសំណល់ថវិកា ឬកង្វះថវិកាដូចមានចែងក្នុងវាក្យខណ្ឌខាងលើ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកែសម្រួលកម្រៃអាជ្ញាបណ្ណឡើងវិញសម្រាប់គម្រោងថវិកាឆ្នាំបន្ទាប់ ។

(*) សូមមើលមាត្រាកែប្រែ ទំព័រ ៣០

ក្នុងករណីកែសម្រួលកម្រៃអាជ្ញាបណ្ណរហូតដល់កម្រិតអតិបរមារួចហើយ ប៉ុន្តែនៅតែពុំអាចទ្រទ្រង់កិច្ចប្រតិបត្តិការរបស់ខ្លួនបាន អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេចកម្រិតអតិបរមានៃកម្រៃអាជ្ញាបណ្ណជាថ្មីឡើងវិញ ។

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យរបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវប្រព្រឹត្តតាមប្រព័ន្ធគណនេយ្យសាធារណៈ និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈជាធរមាន ។

ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវគោរពទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ២៨.- ថ្មី** *

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវមានគណនេយ្យភាពហិរញ្ញវត្ថុចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ។

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវរៀបចំរបាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំឲ្យបានយ៉ាងយឺតបំផុត ១ (មួយ) ខែ ក្រោយឆ្នាំការិយបរិច្ឆេទ ។

របាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំរួមជាមួយនឹងបញ្ជិកាគណនេយ្យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងកំណត់ហេតុពាក់ព័ន្ធ ត្រូវបានធ្វើសវនកម្ម និងត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរសវនកម្មជាតិ ។

ក្នុងរយៈពេល ១ (មួយ)ខែ យ៉ាងយូរបន្ទាប់ពីធ្វើសវនកម្មរួច អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវដាក់របាយការណ៍ទាំងអស់ជូនទៅនាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេចតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ ។

## ជំពូកទី ៥
## ប្រភេទអាជ្ញាបណ្ណ

**មាត្រា ២៩.-**

អាជ្ញាបណ្ណដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ «ក» មាត្រា ៧ នៃច្បាប់នេះមានប្រភេទដូចខាងក្រោម ៖

១. អាជ្ញាបណ្ណផលិតកម្ម

២. អាជ្ញាបណ្ណបញ្ជូន

៣. អាជ្ញាបណ្ណបែងចែក

៤. អាជ្ញាបណ្ណចែកចាយ

៥. អាជ្ញាបណ្ណលក់ដុំ

៦. អាជ្ញាបណ្ណលក់រាយ

៧. អាជ្ញាបណ្ណសេវាកម្មបន្ត និង



( * ) សូមមើលមាត្រាកែប្រែ ទំព័រ ៣០

៨. អាជ្ញាបណ្ណរួម ។

ប្រតិបត្តិការផ្តល់សេវាកម្មអគ្គិសនី ក្រោមអាជ្ញាបណ្ណប្រភេទណាមួយដូចមានចែងក្នុងវាក្យខណ្ឌខាងលើត្រូវមានរូបភាពជាក្រុមហ៊ុនដែលបំពេញតាមនីតិវិធីជាធរមាន ។ ចំពោះប្រតិបត្តិការផ្តល់សេវាកម្មអគ្គិសនីក្រោមអាជ្ញាបណ្ណសម្រាប់ផលិតកម្ម ចែកចាយ និង/ឬលក់រាយអាចដំណើរការជារូបវន្តបុគ្គលបានក្នុងកម្រិតទំហំអាជីវកម្មទ្រង់ទ្រាយតូចដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

**មាត្រា ៣០.-**

អ្នកកាន់អាជ្ញាបណ្ណផលិតកម្មមានសិទ្ធិធ្វើសេវាកម្មផលិតអគ្គិសនីដោយមធ្យោបាយផលិតកម្មជាកំណត់មួយ ។ សិទ្ធិធ្វើសេវាកម្មផលិតអគ្គិសនីក្នុងច្បាប់នេះ គឺសិទ្ធិជាម្ចាស់សិទ្ធិដំណើរការនិងសិទ្ធិគ្រប់គ្រង ឬត្រួតត្រាលើមធ្យោបាយផលិតកម្ម ដើម្បីផលិតអគ្គិសនីលក់ ពុំមែនដើម្បីប្រើប្រាស់ផ្ទាល់ទេ ។

ការផ្តល់អាជ្ញាបណ្ណផលិតកម្ម គឺសម្រាប់គោលបំណងក្នុងការជំរុញកិច្ចដំណើរការដោយសុវត្ថិភាព ស្ថេរភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃបណ្តាញជាតិបញ្ជូនអគ្គិសនី ឬបណ្តាញចែកចាយនិងមធ្យោបាយតភ្ជាប់ ។

សុពលភាពរបស់អាជ្ញាបណ្ណផលិតកម្មជាទូទៅត្រូវកំណត់ស្មើនឹងអាយុកាលប្រើប្រាស់ដោយប្រសិទ្ធភាពនៃមធ្យោបាយផលិតកម្ម លើកលែងតែក្នុងករណីដែលកិច្ចព្រមព្រៀងទិញអគ្គិសនីមានចិរវេលាតិចជាង ។ អាជ្ញាបណ្ណផលិតកម្មអាចដកហូតបានតាមបញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣១.-**

អ្នកកាន់អាជ្ញាបណ្ណបញ្ជូន មានសិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនី ។ សិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនីក្នុងច្បាប់នេះ គឺសិទ្ធិជាម្ចាស់ សិទ្ធិដំណើរការ និងសិទ្ធិគ្រប់គ្រងលើមធ្យោបាយបញ្ជូនអគ្គិសនីដើម្បីផ្ទេរ ប្រគល់ ឬលក់អគ្គិសនីក្នុងបរិមាណធំ ។

អាជ្ញាបណ្ណបញ្ជូនមានពីរប្រភេទគឺអាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីនិងអាជ្ញាបណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។

**មាត្រា ៣២.-**

អាជ្ញាបណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ត្រូវបានផ្តល់ឲ្យអ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនីមួយ ដែលរដ្ឋទទួលខុសត្រូវហើយមានសិទ្ធិសម្រាប់ធ្វើការបញ្ជូនអគ្គិសនីដល់ក្រុមហ៊ុនចែកចាយអគ្គិសនី និងដល់អ្នកប្រើប្រាស់ធំៗ ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងតំបន់ប្រើប្រាស់ប្រព័ន្ធទោលដូចមានចែងក្នុងវាក្យខណ្ឌ ១ នៃមាត្រា ៣៥ និងលើកលែងតែក្នុងករណីមានការផ្តល់សិទ្ធិដោយឡែកឲ្យអ្នកកាន់អាជ្ញាបណ្ណបញ្ជូនក្នុងគោលបំណងពិសេស ដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ។

អាជ្ញាបណ្ណដែលបានចេញស្របតាមមាត្រានេះ អាចមានអាណត្តិមួយមិនកំណត់និងអាចដកហូតបានស្របតាមច្បាប់នេះ ។

**មាត្រា ៣៣.-**

អ្នកកាន់អាជ្ញាបណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសមានសិទ្ធិសាងសង់ធ្វើជាម្ចាស់ និង/ឬដំណើរការលើមធ្យោបាយបញ្ជូនអគ្គិសនីដែលបានកំណត់ជាក់លាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានគោលដៅច្បាស់

លាស់និងធានាដល់ផលប្រយោជន៍សាធារណៈ ។ គោលការណ៍និងលក្ខខណ្ឌសម្រាប់ការផ្តល់អាជ្ញាបណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវកំណត់ដោយបញ្ញត្តិរបស់រាជរដ្ឋាភិបាល ។

សុពលភាពនៃអាជ្ញាបណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស អាចមានរយៈពេលមួយមិនកំណត់ ឬមានកម្រិតត្រឹមអាយុកាលប្រើប្រាស់ដោយប្រសិទ្ធភាពនៃមធ្យោបាយបញ្ជូននោះ ។ អាជ្ញាបណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសអាចដកហូតបានតាមបញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៤.-**

អ្នកកាន់អាជ្ញាបណ្ណចែកចាយមានសិទ្ធិធ្វើសេវាកម្មចែកចាយអគ្គិសនីក្នុងតំបន់ជាកំណត់មួយដែលមានផ្ទៃដីជាប់គ្នា ។ សិទ្ធិធ្វើសេវាកម្មចែកចាយអគ្គិសនីក្នុងច្បាប់នេះ គឺសិទ្ធិជាម្ចាស់ សិទ្ធិដំណើរការ និងសិទ្ធិគ្រប់គ្រង ឬ ត្រួតត្រាលើមធ្យោបាយចែកចាយអគ្គិសនី ដើម្បីផ្ទេរ ផ្គត់ផ្គង់ ឬលក់អគ្គិសនីដល់អ្នកប្រើប្រាស់ ។ ការធ្វើជាម្ចាស់កិច្ចដំណើរការនិងការគ្រប់គ្រង ឬការត្រួតត្រាលើមធ្យោបាយចែកចាយអគ្គិសនី ដែលស្ថិតក្នុងទីតាំងឯកជនដើម្បីសម្រាប់ការផ្គត់ផ្គង់អគ្គិសនីផ្ទាល់ខ្លួន មិនហៅថាសេវាកម្មចែកចាយអគ្គិសនីឡើយ ។

អាជ្ញាប័ណ្ណដែលបានចេញស្របតាមមាត្រានេះ អាចមានអាណត្តិមួយមិនកំណត់ និងអាចដកហូតវិញបានស្របតាមច្បាប់នេះ ។

**មាត្រា ៣៥.-**

អាជ្ញាបណ្ណរួម ជាប្រភេទអាជ្ញាបណ្ណមួយដែលរួមបញ្ចូលអាជ្ញាប័ណ្ណមួយចំនួន ឬទាំងអស់ ដូចមានចែងក្នុងកថាខណ្ឌ ១ ដល់កថាខណ្ឌ ៧ នៃមាត្រា ២៩ នៃច្បាប់នេះ ។

អាជ្ញាបណ្ណរួមអាចចេញឲ្យអគ្គិសនីកម្ពុជា និងប្រព័ន្ធទោល ដើម្បីផ្តល់សិទ្ធិឲ្យផលិត បញ្ជូន បែងចែកចែកចាយ និងលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ ។ ក្នុងករណីបន្ថែមមធ្យោបាយផលិតកម្មអគ្គិសនីថ្មីនីមួយៗ អ្នកកាន់អាជ្ញាបណ្ណរួមត្រូវសុំអាជ្ញាបណ្ណផលិតមកម្មថែមទៀត ។

ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងការប្រកួតប្រជែងដែលនឹងធ្វើឲ្យការចំណាយម៉ាហ្ស៊ីណាល់សម្រាប់ដំណើរការរយៈពេលវែងចុះទាបបំផុត អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវដាក់លក្ខខណ្ឌឲ្យបំបែកសេវាកម្មផលិតកម្មសេវាកម្មបញ្ជូន និងសេវាកម្មចែកចាយអគ្គិសនីចេញពីគ្នា ក្នុងតំបន់សេវាកម្មរបស់អ្នកកាន់អាជ្ញាបណ្ណ ។

**មាត្រា ៣៦.-**

អ្នកកាន់អាជ្ញាបណ្ណបែងចែកអគ្គិសនីមានសិទ្ធិចាត់ចែង គ្រប់គ្រងនិងធ្វើប្រតិបត្តិការលើមធ្យោបាយបែងចែកអគ្គិសនី ដើម្បីសម្របសម្រួលការប្រគល់ និងការទទួលអគ្គិសនីនៃប្រព័ន្ធផលិតកម្ម ប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយ ។

អាជ្ញាបណ្ណបែងចែកអគ្គិសនីត្រូវបញ្ញត្តិអំពីលក្ខខណ្ឌដើម្បីរក្សាកិច្ចដំណើរការនៃប្រព័ន្ធផលិតកម្មអគ្គិសនី ប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយដែលស្ថិតក្នុងរង្វង់សមត្ថកិច្ចបែងចែករបស់ខ្លួនឲ្យមានសុវត្ថិភាព ស្ថេរភាពនិងប្រសិទ្ធភាព ។

អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញអាជ្ញាបណ្ណបែងចែកអគ្គិសនីឲ្យបុគ្គលណាមួយសម្រាប់ធ្វើសេវាកម្មបែងចែកអគ្គិសនីលើប្រព័ន្ធអគ្គិសនីមួយបាន លុះត្រាតែ ៖

១. ប្រព័ន្ធអគ្គិសនីនោះមានបណ្តាញបញ្ជូនតភ្ជាប់តំបន់ចែកចាយសំខាន់ៗច្រើន

២. សេវាកម្មផលិតកម្ម សេវាកម្មបញ្ជូន និងសេវាកម្មចែកចាយបានត្រូវបំបែកចេញពីគ្នារួចរាល់ និង

៣. សេវាកម្មបែងចែកអគ្គិសនីមានទំហំធំគ្រប់គ្រាន់ដែលអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថា អាចឲ្យធ្វើសេវាកម្មដោយឡែកបាន ។

អាជ្ញាបណ្ណដែលបានចេញស្របតាមមាត្រានេះអាចមានអាណត្តិមួយមិនកំណត់និងអាចដកហូតវិញបានស្របតាមច្បាប់នេះ ។

**មាត្រា ៣៧.-**

អ្នកកាន់អាជ្ញាបណ្ណលក់ដុំមានសិទ្ធិចូលរួមទិញអគ្គិសនីពីអ្នកកាន់អាជ្ញាបណ្ណផលិតកម្ម ឬពីប្រព័ន្ធអគ្គិសនីនៃប្រទេសជិតខាងណាមួយ ដើម្បីលក់ឲ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ឬអ្នកប្រើប្រាស់ធំៗនៅក្នុងប្រព័ន្ធអគ្គិសនីជាប់គ្នាមួយ ។

អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញអាជ្ញាបណ្ណលក់ដុំឲ្យបុគ្គលណាមួយសម្រាប់ធ្វើសេវាកម្មបាន នៅពេលណាដែលរាល់លក្ខខណ្ឌទាំងឡាយដែលកំណត់ក្នុងគោលនយោបាយថាមពលរបស់រាជរដ្ឋាភិបាលសម្រាប់អនុញ្ញាតឲ្យមានទីផ្សារលក់ដុំបានត្រូវបំពេញ ។

ទីផ្សារលក់ដុំក្នុងច្បាប់នេះ សំដៅលើទីផ្សារមួយដែលអ្នកផលិតអាចលក់អគ្គិសនីឲ្យអ្នកទិញច្រើនគ្នាបាន និងដែលសេវាកម្មបញ្ជូនបានត្រូវផ្ដាច់ចេញពីសេវាកម្មផលិត និងក្លាយទៅជាសេវាកម្មដែលគ្រាន់តែជាការផ្ដល់សេវាបញ្ជូនដើម្បីកម្រៃ ។ ក្នុងទីផ្សារលក់ដុំការគ្រប់គ្រងទីផ្សារ និងកិច្ចដំណើរការបញ្ជូននឹងត្រូវផ្ដាច់ចេញពីគ្នា ។

សុពលភាពនៃអាជ្ញាបណ្ណលក់ដុំអគ្គិសនីត្រូវមានរយៈពេលមួយកំណត់ និងអាចដកហូតវិញបានតាមបញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៨.-**

ក្នុងការចេញអាជ្ញាបណ្ណរួម អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវយកចិត្តទុកដាក់ចំពោះផែនការសម្រាប់រយៈពេលវែងព្រមទាំងគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយការចំណាយម៉ាហ្សីណាល់សម្រាប់ដំណើរការរយៈពេលវែងលើការផ្គត់ផ្គង់អគ្គិសនីជូនអ្នកប្រើប្រាស់ ការបង្កើតបណ្ដាញជាតិបញ្ជូនអគ្គិសនី និងការពង្រីកបណ្ដាញនោះ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៩.-**

អ្នកកាន់អាជ្ញាបណ្ណលក់រាយមានសិទ្ធិចូលរួមក្នុងការលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ ។ អាជ្ញាប័ណ្ណលក់រាយនីមួយៗ ត្រូវបានកំណត់ឲ្យអនុវត្តលើតំបន់សេវាកម្មជាប់គ្នា ។

អ្នកសុំអាជ្ញាបណ្ណលក់រាយ ត្រូវតែមានកិច្ចសន្យាបន្តពីក្រុមហ៊ុនសេវាកម្មអគ្គិសនីដែលមានអាជ្ញាប័ណ្ណ ហើយកិច្ចសន្យាទាំងនោះ ត្រូវបានដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជាដើម្បីពិនិត្យ និងសម្រេច ។

អគ្គិសនីដែលអ្នកកាន់អាជ្ញាបណ្ណលក់រាយអាចលក់ឲ្យអ្នកប្រើប្រាស់ ត្រូវតែបានជាវពីក្រុមហ៊ុនសេវាកម្មអគ្គិសនី ដែលមានអាជ្ញាបណ្ណក្នុងតំបន់ភូមិសាស្ត្រពាក់ព័ន្ធ រហូតដល់ពេលណាដែលអាជ្ញាធរអគ្គិសនីកម្ពុជាអនុញ្ញាតឲ្យជាវពីអ្នកផ្គត់ផ្គង់អគ្គិសនីផ្សេងទៀតស្របតាមគោលនយោបាយថាមពលជាតិ ។

រាល់អាជ្ញាបណ្ណដែលចេញស្របតាមមាត្រានេះ ត្រូវមានអាណត្តិអតិបរមា ៥ (ប្រាំ) ឆ្នាំ ហើយអាចបន្តទៀតបាននិងអាចដកហូតបានតាមបញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៤០.-**

អ្នកកាន់អាជ្ញាបណ្ណសេវាកម្មបន្តមានសិទ្ធិផ្គត់ផ្គង់សេវាកម្មអគ្គិសនីស្របតាមកិច្ចសន្យាបន្តជាមួយអ្នកដែលមានអាជ្ញាបណ្ណស្រាប់ ។ អាជ្ញាបណ្ណស្របតាមមាត្រានេះត្រូវបញ្ចូលគ្រប់លក្ខខណ្ឌដែលអាចអនុវត្តបាន ព្រមទាំងលក្ខខណ្ឌបន្ថែមនៃអាជ្ញាបណ្ណដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចសន្និដ្ឋានថា ស្ថិតក្នុងផលប្រយោជន៍សាធារណៈ ។

អាជ្ញាធរអគ្គិសនីកម្ពុជាចេញបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងសកម្មភាព និងកិច្ចប្រតិបត្តិការនៃកិច្ចសន្យាបន្តដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចសន្និដ្ឋានថាស្ថិតក្នុងផលប្រយោជន៍សាធារណៈ ។

## ជំពូកទី ៦
## ការចេញអាជ្ញាបណ្ណ

**មាត្រា ៤១.-**

គ្មានបុគ្គលណាមួយអាចដំណើរការជាក្រុមហ៊ុនសេវាកម្មអគ្គិសនី ឬផ្តល់សេវាកម្មអគ្គិសនីបានឡើយ លើកលែងតែបានអនុវត្តស្របតាមខ្លឹមសារនៃអាជ្ញាបណ្ណមានសុពលភាពដែលបានចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

អាជ្ញាបណ្ណត្រូវបានចេញឲ្យចំពោះតែបុគ្គលណាដែលមានសមត្ថភាពសមស្របទៅនឹងការតម្រូវរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីដំណើរការជាក្រុមហ៊ុនសេវាកម្មអគ្គិសនី និងដើម្បីបំពេញកាតព្វកិច្ច និងលក្ខខណ្ឌសេវាកម្ម ដែលមានចុះក្នុងអាជ្ញាប័ណ្ណនោះ ។ មិនត្រូវទាមទារឲ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់សេវាកម្មអគ្គិសនីដែលមានថ្លៃទាបជាងបញ្ជីថ្លៃលក់អគ្គិសនីនោះទេ លើកលែងតែអ្នកប្រើប្រាស់នោះបានទទួលការជួយឧបត្ថម្ភពីមូលនិធិពិសេសណាមួយ ហើយអ្នកកាន់អាជ្ញាបណ្ណក៏មានការឯកភាពទៅលើការចាត់ចែងនោះដែរ ។

**មាត្រា ៤២.- ថ្មី** *

អ្នកកាន់អាជ្ញាបណ្ណនីមួយៗ ត្រូវគោរពគ្រប់លក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាបណ្ណរបស់ខ្លួន បទបញ្ជា និងបទប្បញ្ញត្តិទាំងអស់ ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាអាទិ៍ បណ្តាច្បាប់ដែលពាក់ព័ន្ធដល់កិច្ចដំណើរការការពារបរិស្ថាន សុវត្ថិភាព ពលកម្ម សុខភាព ពន្ធដារ និងអនុវត្តការការពារ និងស្តង់ដានៃប្រព័ន្ធអគ្គិសនី ។ អ្នកកាន់អាជ្ញាបណ្ណត្រូវប្រើប្រាស់ធនធាន និងផ្តល់នូវសេវាផលិតកម្ម បញ្ជូន បែងចែក ឬចែកចាយដែលអាចអនុវត្តបានដោយចំណាយទាបបំផុត និងដោយស្របទៅតាមបទពិសោធយ៉ាងប្រុងប្រយ័ត្នដែលធ្លាប់មានកន្លងមក ។

អនុលោមតាមបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាបណ្ណម្នាក់ៗត្រូវជូនទៅអាជ្ញាធរអគ្គិសនីកម្ពុជា ដោយចម្លងជូនទៅក្រសួងរ៉ែ និងថាមពល និងអាចឲ្យសាធារណជនដឹងបាននូវ ៖

១. របាយការណ៍សង្ខេបប្រចាំឆ្នាំនៃបណ្តាសកម្មភាពរបស់អ្នកកាន់អាជ្ញាបណ្ណក្នុងឆ្នាំកន្លងមក

( * ) សូមមើលមាត្រាកែប្រែ ទំព័រ ៣០

២. ផែនការការងារប្រចាំឆ្នាំដែលរៀបរាប់អំពីសកម្មភាពរបស់អ្នកកាន់អាជ្ញាបណ្ណដែលត្រូវអនុវត្តសម្រាប់ឆ្នាំបន្ទាប់ និង

៣. របាយការណ៍ សេចក្តីប្រកាស និងព័ត៌មានផ្សេងៗទៀត ដែលអាជ្ញាធរអគ្គិសនីកម្ពុជា កំណត់ដោយបទប្បញ្ញត្តិថាចាំបាច់ និងសមស្រប ។

អ្នកកាន់អាជ្ញាបណ្ណផលិតកម្មនីមួយៗត្រូវដាក់ជូនទៅអាជ្ញាធរអគ្គិសនីកម្ពុជាពិនិត្យ និងសម្រេចនូវរបាយការណ៍ សេចក្តីប្រកាស និងព័ត៌មានណាមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ដោយបទប្បញ្ញត្តិថាចាំបាច់សម្រាប់ធានាដំណើរការដោយសុវត្ថិភាព និងស្ថិរភាពបណ្តាញបញ្ជូន និងមធ្យោបាយតភ្ជាប់ ។

**មាត្រា ៤៣.-**

មុននឹងចេញអាជ្ញាបណ្ណ ឬអនុញ្ញាតឲ្យដំណើរការឡើងវិញនូវអាជ្ញាបណ្ណដែលបានព្យួរ អាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឲ្យមានមូលប័ត្រ ឬរូបភាពផ្សេងទៀតនៃការធានាហិរញ្ញវត្ថុដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចទទួលយកបាន សម្រាប់ធានាដល់ការបំពេញកាតព្វកិច្ចសេវាកម្មតាមច្បាប់នេះនិងលក្ខខណ្ឌនៃអាជ្ញាបណ្ណដោយរាប់បញ្ចូលទាំងការទូទាត់កម្រៃអាជ្ញាបណ្ណ ។

**មាត្រា ៤៤.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបង្កើតលក្ខខណ្ឌដើម្បីអនុវត្តលើការចេញ កែសម្រួលព្យួរ ដកហូត ឬបដិសេធអាជ្ញាប័ណ្ណនិងបែបបទដែលស្នើសុំដោយអនុលោមតាមច្បាប់នេះ ។

**មាត្រា ៤៥.-**

ក្រៅពីអ្នកកាន់អាជ្ញាបណ្ណរបស់រដ្ឋ គ្មានអ្នកកាន់អាជ្ញាបណ្ណណាមួយអាចកាន់អាជ្ញាបណ្ណលើសពីមួយ ឬមានភាគហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ជាមួយអ្នកកាន់អាជ្ញាបណ្ណផ្សេងទៀតបានឡើយ ។ លើកលែងតែរាជរដ្ឋាភិបាលនិងក្រុមហ៊ុនរដ្ឋ គ្មានជនណាម្នាក់ដែលជាម្ចាស់ ឬជាអ្នកគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើអ្នកកាន់អាជ្ញាប័ណ្ណមួយអាចមានភាគហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុដោយផ្ទាល់ជាមួយអ្នកកាន់អាជ្ញាបណ្ណណាមួយផ្សេងទៀតឡើយ ។

អ្នកកាន់អាជ្ញាបណ្ណមិនអាចជួល លក់ ឬបញ្ចាំអាជ្ញាបណ្ណរបស់ខ្លួនទៅឲ្យជនណាផ្សេងទៀតបានឡើយ ។ ការបោះបង់ ឬផ្ទេរអាជ្ញាប័ណ្ណរបស់ខ្លួនទៅឲ្យជនណាផ្សេងទៀតអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតជាពិសេសពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ ដោយឡែក រាជរដ្ឋាភិបាលអាចផ្ទេរអាជ្ញាបណ្ណដែលកាន់កាប់ដោយរដ្ឋ ឬដោយក្រុមហ៊ុនរដ្ឋដែលជាផ្នែកមួយនៃការកែទំរង់វិស័យអគ្គិសនី ។

តាមគោលបំណងនៃច្បាប់នេះនិងស្របតាមផលប្រយោជន៍សាធារណៈ អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុម័តបដិសេធ ឬដាក់កំហិតលើបណ្តាសកម្មភាព ៖

- ការរួមសម្បត្តិពាណិជ្ជកម្ម ឬការរៀបចំឡើងវិញ ការទិញយក ឬការលក់អចលនទ្រព្យ ឬវត្ថុធានា ឬ
- ការបង្កើនសកម្មភាពពាណិជ្ជកម្មរបស់អ្នកកាន់អាជ្ញាបណ្ណ ។

## ជំពូកទី ៧
## បញ្ជីថ្លៃលក់អគ្គិសនី

**មាត្រា ៤៦.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់ និងពិនិត្យឡើងវិញលើអត្រាថ្លៃលក់ ថ្លៃសេវា និងលក្ខខណ្ឌសេវាកម្មរបស់អ្នកកាន់អាជ្ញាបណ្ណ ។ ក្នុងកំឡុងពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំរបស់អ្នកកាន់អាជ្ញាបណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវអនុម័តកែប្រែ ឬបដិសេធចោលសំណើដែលស្នើសុំកំណត់ ឬសុំផ្លាស់ប្តូរបញ្ជីថ្លៃលក់នោះ ។

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់ថ្ងៃចូលជាធរមាននៃបញ្ជីថ្លៃលក់អគ្គិសនីថ្មី ឬថ្លៃកែសម្រួលឡើងវិញដែលមិនត្រូវឲ្យហួសរយៈពេល ៩០(កៅសិប)ថ្ងៃ ដូចបានកំណត់ខាងលើ ។

**មាត្រា ៤៧.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបង្កើតបែបបទ និងគំរូសម្រាប់អនុវត្តក្នុងការដាក់ពាក្យស្នើសុំអនុម័តបញ្ជីថ្លៃលក់អគ្គិសនីដោយអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបង្កើតបទបញ្ជាសម្រាប់អ្នកកាន់អាជ្ញាបណ្ណដែលពាក់ព័ន្ធនឹង ៖

- ការតម្រូវដាក់ស្តែងសម្រាប់ការស្នើសុំអនុម័តបញ្ជីថ្លៃលក់អគ្គិសនីដោយរាប់បញ្ចូលទាំងព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មរួចហើយ
- រយៈពេលសម្រាប់ការស្នើសុំអនុម័តនិងសេចក្តីសម្រេចបញ្ជីថ្លៃលក់អគ្គិសនី
- នីតិវិធីសម្រាប់អ្នកប្រើប្រាស់និងភាគីដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់មតិលើការស្នើសុំអនុម័តបញ្ជីថ្លៃលក់អគ្គិសនី និង
- នីតិវិធីសម្រាប់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការទទួលព័ត៌មានបន្ថែមចាំបាច់ពីអ្នកដាក់ពាក្យសុំសម្រាប់វាយតម្លៃលើការស្នើសុំអនុម័តបញ្ជីថ្លៃលក់អគ្គិសនី ។

**មាត្រា ៤៨.-**

បញ្ជីថ្លៃលក់អគ្គិសនីដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវ ៖

១- ការពារអ្នកប្រើប្រាស់ទល់នឹងការកំណត់ថ្លៃផ្តាច់មុខ

២- ផ្តល់លទ្ធភាពឲ្យអ្នកកាន់អាជ្ញាបណ្ណអាចរំលោះចំណាយរបស់គេ ប៉ុន្តែចំណាយនេះត្រូវជាចំណាយត្រឹមត្រូវតាមគោលការណ៍នៃការធ្វើអាជីវកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ

៣- លើកទឹកចិត្តចំពោះប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងការគ្រប់គ្រងផ្ទៃក្នុងរបស់អ្នកកាន់អាជ្ញាបណ្ណដោយអនុញ្ញាតឲ្យបង្កើនចំណូលហិរញ្ញវត្ថុស្របតាមការបន្ថយចំណាយក្នុងការផ្តល់សេវាកម្ម ឲ្យតែអ្នកកាន់អាជ្ញាបណ្ណនោះបានធានាការផ្គត់ផ្គង់និងគុណភាពសេវាតាមការតម្រូវនៃអាជ្ញាបណ្ណរបស់ខ្លួន

៤- លើកទឹកចិត្តចំពោះប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងវិស័យអគ្គិសនី ដោយឆ្លុះបញ្ចាំងអំពីចំណាយម៉ាហ្ស៊ីណាល់សម្រាប់រយៈពេលខ្លីនិងរយៈពេលវែង និងដោយចង្អុលបង្ហាញថ្លៃពិតប្រាកដ យោងទៅតាមភាពបរិបូរណ៍ ឬកង្វះក្នុងការផ្គត់ផ្គង់សេវាកម្មអគ្គិសនី

៥- គិតដល់ចំណាយនិងភាពខុសគ្នាជាក់ស្តែងរវាងប្រភេទអ្នកជាវនិងប្រភេទសេវា និងដល់ការបំពេញខាតណាមួយដែលរាជរដ្ឋាភិបាលផ្តល់ឲ្យសម្រាប់ឧបត្ថម្ភអ្នកជាវ ឬប្រភេទនៃអ្នកជាវណាមួយ ប៉ុន្តែមិនមានគោលនយោបាយណាមួយរបស់រាជរដ្ឋាភិបាលឃាត់ឃាំងអ្នកកាន់អាជ្ញាប័ណ្ណ ក្នុងការអនុវត្តន៍សិទ្ធិដែលបានផ្តល់ឲ្យនៅក្នុងអាជ្ញាបណ្ណ ក្នុងការផ្តាច់ចរន្តរបស់អ្នកប្រើប្រាស់សាធារណៈ ឬឯកជនណាមួយ ដោយសារការខកខានមិនបានបំពេញកាតព្វកិច្ចទូទាត់តាមកិច្ចសន្យា ឬបណ្តាលក្ខខណ្ឌនៃសេវាកម្មដែលបានអនុម័ត ។

ចំណែកនៃប្រាក់ចំណូលសម្រាប់ស្រង់យកវិញនូវចំណាយលើកម្រៃអាជ្ញាបណ្ណត្រូវបានលៃទុកដើម្បីអាចរំលោះចំណាយនោះបានមកវិញពីប្រភេទអ្នកជាវនីមួយៗតាមសមាមាត្រនៃចំណាយសម្រាប់ការផ្តល់សេវាឲ្យអ្នកជាវប្រភេទនោះ ។

បញ្ជីថ្លៃលក់អគ្គិសនីអាចបង្កើតខុសៗគ្នាសម្រាប់ប្រភេទនីមួយៗដើម្បីឆ្លុះបញ្ចាំងបរិមាណប្រើប្រាស់អតិបរមា បរិមាណប្រើប្រាស់មធ្យម ឬបរិមាណប្រើប្រាស់អគ្គិសនីជារួមក្នុងពេលវេលាខុសៗគ្នាតាមរដូវកាល តាមពេលម៉ោងក្នុងថ្ងៃ ឬឆ្នាំ ប្រភេទសេវាដែលបានទិញ ឬកត្តាប្រហាក់ប្រហែលផ្សេងទៀត ។ អាចបង្កើតអត្រាថ្លៃទាបជាងសម្រាប់ការប្រើប្រាស់តិច ឬសម្រាប់លំនៅដ្ឋានក្រីក្រ និងសម្រាប់អ្នកជាវនៅជនបទដើម្បីធានាឲ្យអ្នកទាំងនោះមានអគ្គិសនីប្រើប្រាស់ ។ បញ្ជីថ្លៃលក់អគ្គិសនីដែលផ្អែកលើការអនុវត្តន៍ជាក់ស្តែងដោយគិតបញ្ចូលទាំងការដាក់សន្ទស្សន៍លើប្រាក់ចំណូល សន្ទស្សន៍លើថ្លៃនិងវិធីសាស្ត្រនៃការរៀបចំថ្លៃលក់អគ្គិសនីផ្សេងទៀតអាចត្រូវបានប្រើប្រាស់ផងដែរ ប្រសិនបើអាជ្ញាធរអគ្គិសនីកម្ពុជាយល់ឃើញថា ការប្រើប្រាស់វិធីសាស្ត្រទាំងនោះ ធានាផលប្រយោជន៍របស់អ្នកកាន់អាជ្ញាបណ្ណ និងអ្នកប្រើប្រាស់ ។

## ជំពូកទី ៨
## បទប្បញ្ញត្តិផ្សេងទៀតលើសេវាកម្មអគ្គិសនី

### មាត្រា ៤៩.-

អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបង្កើតបែបបទនិងស្តង់ដា ដើម្បីទទួលពីអ្នកកាន់អាជ្ញាបណ្ណនូវព័ត៌មានដែលពាក់ព័ន្ធនឹងកម្មវិធីវិនិយោគនិងកម្មវិធីទទួលអគ្គិសនី ។

### មាត្រា ៥០.-

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតម្រូវឲ្យអ្នកកាន់អាជ្ញាបណ្ណនីមួយៗធានានិងបញ្ជាក់ថា បរិធានសម្រាប់កត់ត្រានិងឧបករណ៍សម្រាប់ធ្វើការសាកល្បងនាឡិកាស្ទង់ ត្រឹមត្រូវតាមស្តង់ដាដែលត្រូវអនុវត្តតាម ។ អ្នកកាន់អាជ្ញាបណ្ណត្រូវវាស់បរិមាណអគ្គិសនីដោយប្រើប្រាស់តែបរិធានសម្រាប់កត់ត្រាណាដែលបានផ្ទៀងផ្ទាត់ដោយឧបករណ៍សាកល្បង ដែលបានបញ្ជាក់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ បរិធានសម្រាប់កត់ត្រា និងឧបករណ៍សម្រាប់ធ្វើការសាកល្បងនាឡិកាស្ទង់អាចត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធានាភាពត្រឹមត្រូវជានិរន្តរ៍តាមស្តង់ដាដែលត្រូវអនុវត្តតាមនិងតាមការតម្រូវដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃការវាស់ស្ទង់អគ្គិសនីដែលបានផ្គត់ផ្គង់ អ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកប្រើប្រាស់អគ្គិសនីត្រូវអនុញ្ញាតឲ្យមន្ត្រីអាជ្ញាធរអគ្គិសនីកម្ពុជាត្រួតពិនិត្យ និងសាកល្បងនាឡិកាស្ទង់ និងឧបករណ៍សម្រាប់សាកល្បងនាឡិកាស្ទង់ ដោយមិនចាំបាច់មានលិខិតជូនដំណឹងជាមុន ។

**មាត្រា ៥១.-**

អ្នកកាន់អាជ្ញាបណ្ណត្រូវ ៖

១- ដាក់បរិធានសម្រាប់កត់ត្រានៅទីកន្លែងសមស្របជាងគេដែលងាយស្រួលសម្រាប់កត់ត្រា និងអាចឲ្យអ្នកប្រើប្រាស់ថែរក្សាសុវត្ថិភាពបរិធាននោះបាន

២- មានសិទ្ធិសាកល្បង ផ្លាស់ប្តូរ និងធ្វើឲ្យទាន់សម័យនូវបរិធានសម្រាប់កត់ត្រាដោយទទួលបន្ទុកចំណាយសម្រាប់ការងារនិងបរិធានទាំងនោះ ។

៣- ត្រួតពិនិត្យនិងកែតម្រូវឡើងវិញនូវបរិធានសម្រាប់កត់ត្រាតាមសំណូមពររបស់អ្នកប្រើប្រាស់ និងប្រសិន បើចាំបាច់ត្រូវដាក់បរិធានកត់ត្រាបណ្តោះអាសន្នបើបរិធានមុនតម្រូវឲ្យដោះចេញ និងជួសជុល ។

រាល់ចំណាយសម្រាប់ធ្វើការសាកល្បង ការកែតម្រូវ ការត្រួតពិនិត្យនិងការផ្លាស់ប្តូរត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

**មាត្រា ៥២.-**

អ្នកប្រើប្រាស់ ៖

១- ត្រូវរាយការណ៍ពីដំណើរមិនប្រក្រតីណាមួយដែលបានសង្កេតឃើញ និងបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យ ការជួសជុល ឬការផ្លាស់ប្តូរបរិធាននោះដោយអ្នកកាន់អាជ្ញាបណ្ណ នៅពេលមានលិខិតជូនដំណឹងសមហេតុផល និង

២- អាចមានបរិធានកត់ត្រាផ្ទាល់ខ្លួន ប្រសិនបើបរិធាននោះបំពេញគ្រប់ស្តង់ដា និងការតម្រូវដែលបានកំណត់

**មាត្រា ៥៣.-**

អ្នកកាន់អាជ្ញាបណ្ណទាំងអស់ត្រូវប្រើប្រាស់ប្រព័ន្ធគណនីឯកភាពមួយ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីរាយការណ៍អំពីហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ។

អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដែលធ្វើឡើងដោយអ្នកកាន់អាជ្ញាបណ្ណ និងធ្វើការវិភាគផ្ទាល់ ដើម្បីជាមូលដ្ឋានសម្រាប់គណនាបញ្ជីថ្លៃលក់អគ្គិសនី ។

**មាត្រា ៥៤.-**

អ្នកប្រើប្រាស់ត្រូវអនុញ្ញាតឲ្យតំណាងស្របច្បាប់របស់អ្នកកាន់អាជ្ញាបណ្ណចូលទៅកាន់ទីតាំងរបស់ខ្លួនដើម្បីត្រួតពិនិត្យ ជួសជុលនិងថែទាំនូវនាឡិកាស្ទង់និងមធ្យោបាយអគ្គិសនី ព្រមទាំងកាត់ផ្តាច់សេវាតាមច្បាប់ និងពិនិត្យភាពសមស្របនៃទីតាំងសម្រាប់ការសាងសង់ ឬការតំឡើងមធ្យោបាយនិងបរិក្ខារអគ្គិសនីក្រោយពីបានទទួលសេចក្តីជូនដំណឹងយ៉ាងតិច ២៤ម៉ោង មុនកិច្ចប្រតិបត្តិការ ។ ក្នុងករណីមានគ្រោះអាសន្នអ្នកកាន់

អាជ្ញាបណ្ណ ឬតំណាងស្របច្បាប់របស់ខ្លួនមានសិទ្ធិចូលទៅកាន់ទីតាំងនោះដោយមិនចាំបាច់មានលិខិតជូនដំណឹងជាមុន ។

**មាត្រា ៥៥.-**

អ្នកកាន់អាជ្ញាបណ្ណអាចរៀបចំសាងសង់ ឬតំឡើងនូវមធ្យោបាយបរិក្ខារ និងបណ្ដាញអគ្គិសនីដែលចាំបាច់ ដើម្បីផ្គត់ផ្គង់អគ្គិសនី និងបំពេញកាតព្វកិច្ចសេវាកម្មរបស់ខ្លួនស្របតាមច្បាប់នេះ ។

អ្នកកាន់អាជ្ញាបណ្ណត្រូវខិតខំដោះស្រាយតាមរយៈការចរចាសម្របសម្រួលជាមួយម្ចាស់ដីនិងដោយការបង់ទូទាត់សងសមស្របនិងយុត្តិធម៌ដើម្បីមានសិទ្ធិចូល សិទ្ធិឆ្លងកាត់ និង/ឬសិទ្ធិប្រើប្រាស់ដីធ្លី ។

ក្នុងករណីដែលអ្នកកាន់អាជ្ញាបណ្ណជួបនូវឧបសគ្គមិនអាចដោះស្រាយបាន ដូចមានចែងក្នុងវាក្យខណ្ឌខាងលើ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើអន្តរាគមន៍ទៅអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយបញ្ហានេះដើម្បីជាផលប្រយោជន៍សាធារណៈ ។

**មាត្រា ៥៦.-**

អ្នកកាន់អាជ្ញាបណ្ណជាអ្នកទទួលខុសត្រូវលើរាល់សកម្មភាពរបស់និយោជិតខ្លួនក្នុងកិច្ចប្រតិបត្តិការសេវាកម្មអគ្គិសនី ។

## ជំពូកទី ៩
## សិទ្ធិអំណាចក្នុងការប្រតិបត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

**មាត្រា ៥៧.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវប្ដឹងទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា អំពីការរំលោភច្បាប់នេះ និងការរំលោភបំពានលើបទប្បញ្ញត្តិ បទបញ្ជា សេចក្ដីសម្រេចព្រមទាំងអាជ្ញាបណ្ណដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

**មាត្រា ៥៨.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវចេញបទប្បញ្ញត្តិដើម្បីកំណត់អំពីនីតិវិធី សម្រាប់ការដាក់ទណ្ឌកម្ម និងទឹកប្រាក់ពិន័យ ប្រភេទនៃការពិន័យដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចដាក់ចំពោះការរំលោភលើអាជ្ញាប័ណ្ណ ព្រមទាំងនីតិវិធីដែលកំណត់អំពីការដកហូតអាជ្ញាបណ្ណ និងលក្ខខណ្ឌដែលត្រូវអនុវត្តទៅលើកិច្ចដំណើរការជាប្រចាំនៃមធ្យោបាយដែលគ្រប់គ្រងដោយអាជ្ញាបណ្ណ ។

**មាត្រា ៥៩.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់នីតិវិធីដែលមានសេចក្ដីណែនាំនិងនីតិវិធីទទួលសេចក្ដីណែនាំសម្រាប់អនុវត្តក្នុងការបញ្ចប់សេវាកម្មអគ្គិសនីដោយអ្នកកាន់អាជ្ញាបណ្ណ ក្នុងករណីដែលមិនមានការទូទាត់ ។ សេចក្ដីណែនាំនោះ ត្រូវបញ្ជាក់អំពីការដាក់ពិន័យដោយការទូទាត់ការប្រាក់ និងថ្លៃឈ្នួលសម្រាប់ការផ្ដាច់ ឬការភ្ជាប់ចរន្តឡើងវិញ ព្រមទាំងមធ្យោបាយសមស្របផ្សេងទៀត ដើម្បីជានាឲ្យអ្នកកាន់អាជ្ញាបណ្ណអាចប្រមូលបាន

ដោយពេញលេញនូវចំណាយទាំងអស់ដែលពាក់ព័ន្ធការទូទាត់ប្រាក់ជំពាក់ ហើយដែលការចាត់ចែងទាំងនោះជានាបានភាពយុត្តិធម៌ដល់អ្នកប្រើប្រាស់ ។

**មាត្រា ៦០.-**

អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកប្រើប្រាស់ណាមួយដែលជាភាគីក្នុងវិវាទពាក់ព័ន្ធដល់ការផ្គត់ផ្គង់សេវាកម្មអគ្គិសនី តាមបញ្ជីថ្លៃលក់អគ្គិសនី ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ឬតាមកិច្ចសន្យាអាចបញ្ជូនវិវាទនោះទៅឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាដោះស្រាយ បើអាជ្ញាបណ្ណដែលពាក់ព័ន្ធនោះតម្រូវឲ្យបញ្ជូនវិវាទនោះទៅអាជ្ញាធរអគ្គិសនីកម្ពុជា ។

ជនដែលពាក់ព័ន្ធអាចដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរទៅអាជ្ញាធរអគ្គិសនីកម្ពុជា តវ៉ាចំពោះអ្នកកាន់អាជ្ញាបណ្ណអំពីការរំលោភបំពានលើបញ្ញត្តិណាមួយនៃច្បាប់នេះ ។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវស៊ើបអង្កេតអំពីពាក្យបណ្តឹងនោះ ។ ក្នុងករណីដែលអាជ្ញាធរអគ្គិសនីកម្ពុជាពិនិត្យឃើញថា មានការរំលោភបំពានមែននោះ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់អ្នកកាន់អាជ្ញាប័ណ្ណអំពីបណ្តឹងតវ៉ា ហើយទុកឱកាសឲ្យអ្នកកាន់អាជ្ញាបណ្ណឆ្លើយតបជាលាយល័ក្ខណ៍អក្សរ ។ ក្នុងករណីណាមួយក៏ដោយ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវជូនព័ត៌មានដល់អ្នកដាក់ពាក្យបណ្តឹងវិញ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ ។

## ជំពូកទី ១០
## ការគ្រប់គ្រង

**មាត្រា ៦១.-**

បទប្បញ្ញត្តិទាំងឡាយដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវប្រកាសផ្សាយជាសាធារណៈ និងត្រូវមានអនុភាពចាប់ពីពេលប្រកាសផ្សាយនោះ ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកែសម្រួលបទប្បញ្ញត្តិដែលបានចេញនៅពេលណាមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថា សមស្របហើយការកែសម្រួលនោះត្រូវមានអនុភាពនៅពេលធ្វើការប្រកាសផ្សាយជាសាធារណៈ ។

**មាត្រា ៦២.-**

អាជ្ញាធរអគ្គិសនីកម្ពុជាអាចស៊ើបរកការពិត លក្ខណៈ សកម្មភាព ឬហេតុការណ៍ណាមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចពិនិត្យឃើញថាចាំបាច់ ឬសមស្រប ដើម្បីកំណត់ថា ជនណាមួយបានរំលោភ ឬប៉ុនប៉ងនឹងរំលោភលើបញ្ញត្តិណាមួយនៃច្បាប់នេះ ឬអនុក្រឹត្យ បទប្បញ្ញត្តិ បទបញ្ជា ឬសេចក្តីសម្រេចណាមួយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

**មាត្រា ៦៣.-**

រាល់បទបញ្ជា បទប្បញ្ញត្តិ ការដោះស្រាយនិងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា រួមទាំងការពន្យល់បកស្រាយជាលាយល័ក្ខណ៍អក្សរត្រូវដាក់ជូនបណ្តាភាគីដែលពាក់ព័ន្ធ ហើយត្រូវផ្ញើឯកសារចម្លងជូនរាជរដ្ឋាភិបាល ។ លើសពីនេះទៀត រាល់បទបញ្ជា បទប្បញ្ញត្តិ ការដោះស្រាយនិងសេចក្តីសម្រេចត្រូវមានសម្រាប់សាធារណជនដោយឥតគិតថ្លៃ នៅការិយាល័យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវទាម

ទារឲ្យមានសម្រាប់សាធារណជនពិនិត្យនូវរាល់អាជ្ញាបណ្ណ និងរាល់បញ្ជីថ្លៃលក់អគ្គិសនី ថ្លៃបន្ទុកផ្សេងៗ និងលក្ខខណ្ឌសេវាកម្មដែលបានអនុម័តរួចរបស់អ្នកកាន់អាជ្ញាបណ្ណនីមួយៗ នៅការិយាល័យសំខាន់ៗរបស់អ្នកកាន់អាជ្ញាបណ្ណនិងនៅទីកន្លែងផ្សេងៗទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជាតម្រូវស្របតាមផលប្រយោជន៍សាធារណៈ។

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

### មាត្រា ៦៤.-

ត្រូវពិន័យជាប្រាក់លើអ្នកកាន់អាជ្ញាបណ្ណ និងនិយោជិតរបស់អ្នកកាន់អាជ្ញាបណ្ណពី ៤០០.០០០ (បួនរយពាន់)រៀល ដល់ ៤.០០០.០០០ (បួនលាន) រៀល ចំពោះការប្រព្រឹត្តិល្មើសមួយដង ក្នុងមួយថ្ងៃ សម្រាប់ថ្ងៃនីមួយៗ ដែលការប្រព្រឹត្តិល្មើសលើបទប្បញ្ញត្តិកើតឡើង ។ ក្នុងករណីមានការប្រព្រឹត្តិល្មើសបន្តទៀត អាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចបញ្ឈប់សកម្មភាពនិងចាត់វិធានការស្របច្បាប់ផ្សេងទៀត ។

### មាត្រា ៦៥.-

ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណប្រព្រឹត្តខុសឆ្គងជាក់ស្តែង ធ្ងន់ធ្ងរ ក្នុងការមិនគោរពលើលក្ខខណ្ឌនៃអាជ្ញាបណ្ណរបស់ខ្លួន អាជ្ញាធរអគ្គិសនីកម្ពុជាមានសិទ្ធិព្យួរទុក ឬដកហូតអាជ្ញាបណ្ណនោះនិងបញ្ជូនសំណុំរឿងទៅតុលាការ ។

ប៉ុន្តែបើអាជ្ញាធរអគ្គិសនីកម្ពុជារកឃើញថា ផលប្រយោជន៍សាធារណៈតម្រូវមិនទាន់ឲ្យដកហូតអាជ្ញាប័ណ្ណនោះទេ អាជ្ញាធរអគ្គិសនីកម្ពុជាអាចជំនួសការដកហូតដោយការដាក់ពិន័យដូចមានចែងក្នុងមាត្រា ៦៤ ខាងលើ រហូតដល់មានអ្នកកាន់អាជ្ញាបណ្ណថ្មីមកជំនួស ។

### មាត្រា ៦៦.-

បន្ថែមលើការពិន័យ ដែលបានកំណត់ក្នុងមាត្រា ៦៤ ត្រូវពិន័យជាប្រាក់ពីមួយដង ដល់បីដងនៃថ្លៃថាមពលអគ្គិសនីដែលបានលួចបន្លំដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត ចំពោះអ្នកកាន់អាជ្ញាបណ្ណដែលបានលួចបន្លំដោយចេតនាធ្វើឲ្យការកត់ត្រាអគ្គិសនីលើសពីការប្រើប្រាស់ជាក់ស្តែងរបស់អ្នកប្រើប្រាស់ ។

### មាត្រា ៦៧.-

ត្រូវពិន័យជាប្រាក់ពី ៤០០.០០០ (បួនរយពាន់)រៀល ដល់ ៤.០០០.០០០ (បួនលាន) រៀលក្នុងមួយថ្ងៃ សម្រាប់រៀងរាល់ថ្ងៃ ចំពោះបុគ្គលដែលបានផ្តល់សេវាកម្មអគ្គិសនីដោយគ្មានអាជ្ញាបណ្ណ ។

### មាត្រា ៦៨.-

ត្រូវពិន័យជាប្រាក់ពីមួយដង ដល់បីដង នៃថ្លៃអគ្គិសនីប្រចាំខែដោយគិតតាមមធ្យមភាគថ្លៃបរិមាណអគ្គិសនីដែលប្រើប្រាស់ ៣ (បី) ខែ មុនពេលប្រព្រឹត្តល្មើស ឬគិតតាមឧបករណ៍ប្រើប្រាស់ជាក់ស្តែងចំពោះជនណាដែលលួចអគ្គិសនីដោយប្រើប្រាស់ក្រៅនាឡិកាស្ទង់ រុះរើ ឬធ្វើឲ្យនាឡិកាស្ទង់ខូច ឬដើរមិនប្រក្រតី ឬដោយវិធីណាផ្សេងទៀត ដោយមិនទាន់គិតដល់សំណងនៃការខូចខាត ។ អ្នកប្រព្រឹត្តល្មើសត្រូវបង់ប្រាក់រំលឹកថ្លៃអគ្គិសនី

ដែលបានលួចដោយគិតតាមបរិមាណអគ្គិសនីប្រើប្រាស់មធ្យមប្រចាំខែខាងលើ តែមិនឲ្យលើសពីថ្លៃប្រើប្រាស់មធ្យម ១២ (ដប់ពីរ) ខែ ។

**មាត្រា ៦៩.-**

ការលួច ការរុះរើ ឬការធ្វើឲ្យខូចខាតដោយចេតនាដល់ឋបនភ័ណ្ឌ មធ្យោបាយ ឬបរិក្ខារផ្គត់ផ្គង់របស់អ្នកកាន់អាជ្ញាបណ្ណអគ្គិសនី ត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ហើយត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ៤០.០០០.០០០ (សែសិបលាន)រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៣ (បី) ឆ្នាំ ឬទោសទាំងពីរ ដោយមិនទាន់គិតដល់សំណងនៃការខូចខាត ។

**មាត្រា ៧០.-**

មន្ត្រីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាណា ដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ត្រូវទទួលទោសរដ្ឋបាល ដោយពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ។

## ជំពូកទី ១២
## អន្តរប្បញ្ញត្តិ

**មាត្រា ៧១.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបង្កើតឡើងនៅពេលដែលច្បាប់នេះចូលជាធរមាន ។

**មាត្រា ៧២.-**

មិនលើសពី ៣ (បី)ខែ ក្រោយពេលដែលច្បាប់នេះចូលជាធរមានក្នុងអាណត្តិដំបូងនាយករដ្ឋមន្ត្រីត្រូវស្នើតែងតាំងប្រធានអាជ្ញាធរអគ្គិសនីកម្ពុជាមួយរូបដែលមានអាណត្តិ ៣(បី) ឆ្នាំ និងសមាជិកពីររូបទៀត ដែលសមាជិកទីមួយអាណត្តិ ២(ពីរ)ឆ្នាំ និងសមាជិកទីពីរត្រូវមានអាណត្តិ ១ (មួយ) ឆ្នាំ ។

**មាត្រា ៧៣.-**

កិច្ចប្រតិបត្តិការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបានផ្តល់មូលនិធិដំបូងពីរាជរដ្ឋាភិបាលក្នុងពេលតែងតាំងប្រធាន ។ មូលនិធិនេះត្រូវដាក់តម្កល់ក្នុងគណនីដោយឡែករបស់អាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ការប្រើប្រាស់របស់ខ្លួន ។

**មាត្រា ៧៤.- ថ្មី** *

ក្រសួងរ៉ែ និងថាមពលត្រូវផ្ទេរតួនាទី និងភារកិច្ចដែលត្រូវប្រគល់ជូនទៅអាជ្ញាធរអគ្គិសនីកម្ពុជាដោយច្បាប់នេះជាបណ្តើរៗ តាមនីតិវិធីសមស្របនៅពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចាប់ផ្តើមដំណើរការ ។

**មាត្រា ៧៥.-**

អ្នកដែលកំពុងផ្តល់សេវាកម្មអគ្គិសនីទាំងអស់ ត្រូវសុំអាជ្ញាបណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជា ៦ (ប្រាំមួយ) ខែយ៉ាងយូរ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

( * ) សូមមើលមាត្រាកែប្រែ ទំព័រ ៣០

**មាត្រា ៧៦.-**

នៅពេលដែលច្បាប់នេះចូលជាធរមាន ប្រសិនបើមិនមានការព្រមព្រៀងពីគ្រប់ភាគីទេ អាជ្ញាធរអគ្គិសនីកម្ពុជាមិនត្រូវចេញបទបញ្ជា ឬបទប្បញ្ញត្តិណាមួយដែលបង្រួម ឬពង្រីកនូវសិទ្ធិនិងកាតព្វកិច្ចដែលបានផ្តល់ឲ្យអ្នកកាន់អាជ្ញាបណ្ណខុសពីកិច្ចសន្យាដែលមានស្រាប់ ដោយរាប់បញ្ចូលទាំងសិទ្ធិក្នុងការប្រមូលមកវិញនូវថ្លៃអគ្គិសនី ឬ បន្ទុកផ្សេងៗទៀត ។

**មាត្រា ៧៧.-**

ក្រោយពេលច្បាប់នេះចូលជាធរមាន អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវចេញបញ្ញត្តិណែនាំរាល់ការប្រើប្រាស់មធ្យោបាយផលិតអគ្គិសនីផ្ទាល់ដែលប៉ះពាល់ដល់បរិស្ថាន ។

## ជំពូកទី ១៣
## អវសានប្បញ្ញត្តិ

**មាត្រា ៧៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧៩.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

( * ) កំណត់សម្គាល់ ៖ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១ នេះ បានធ្វើវិសោធនកម្មចំនួនពីរលើក ។

ការកែប្រែច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាលើកទី ១
(ការផ្តល់សច្ចានុម័តនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧)

- ការកែប្រែទៅលើមាត្រា ៩

ការកែប្រែច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាលើកទី ២
(ការផ្តល់សច្ចានុម័តនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥)

- ការកែប្រែទៅលើមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤